# ផែនការអទ្ធិភាព របស់មជ្ឈមណ្ឌលជាតិ ប្រយុទ្ធនឹង ជំងឺគ្រុនចាញ់ ឆ្នាំ២០១៣

**ស៊ីវ សុវណ្ណារ័ត្ន**

ប្រធានការិយាល័យបច្ចេកទេស មជ្ឈមណ្ឌលជាតិ ប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ

ភ្នំពេញ, ២១ - ២២ មិនា ២០១៣

# ផ្លូវឆ្ពោះទៅមុខរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រឆ្នាំ២០១៣

## លើការប្រតិបត្តិគំរោងស្របទៅតាមផែនការយុទ្ធសាស្ត្រជាតិសំរាប់រយៈពេលយូរដើម្បីលប់បំបាត់ជំងឺគ្រុនចាញ់នៅក្នុងប្រទេសកម្ពុជា (២០១២.២០២៥)

## បន្តលើការអនុវត្តគំរោង GF SSF និង សហការជាមួយដៃគូរអភិវឌ្ឍន៍ WHO, USAID,…

1. **ធានា និងធ្វើឲ្យកាន់តែប្រសើរឡើងនូវការផ្តល់សេវាធ្វើរោគវិនិច្ឆ័យ និង ព្យាបាលជំងឺ គ្រុនចាញ់:**

- បន្តពង្រឹងសេវាសុខាភិបាលសាធារណៈ និង ពង្រីកសកម្មភាពអ្នកស្ម័គ្រចិត្តព្យាបាលជំងឺគ្រុនចាញ់ភូមិ អោយបានគ្រប់ភូមិគោលដៅក្នុងដំណាច់ឆ្នាំ២០១៨ៗ
- អនុវត្តជាទូទៅ DOT ចំពោះសេវាអ្នកស្ម័គ្រចិត្តព្យាបាលជំងឺគ្រុនចាញ់ភូមិ
- ពង្រីកសកម្មភាពអ្នកស្ម័គ្រចិត្តព្យាបាលជំងឺគ្រុនចាញ់ភូមិចល័ត ដោយសហការជាមួយ បុគ្គលិកសុខាភិបាល អជ្ញាធរមូលដ្ឋាន អង្គការដៃគូរ និយោជក ក្រុមហ៊ុនឯកជន....
- បន្តការសិក្សាការព្យាបាលគ្រុនចាញ់ប្រភេទ ប្លាស់ម៉ូដ្យូមវីវ៉ាក់ ដោយប្រើថ្នាំ ព្រីម៉ាគីន
- ពង្រីកសកម្មភាព សហការ ជាមួយសេវាព្យាបាលឯកជន ដោយសហការជាមួយ បុគ្គលិកសុខាភិបាល អជ្ញាធរមូលដ្ឋាន អង្គការដៃគូរ
- លើកកំពស់សមត្ថភាព អ្នកមើលមីក្រូទស្សន៍ និងគុណភាព កញ្ចក់ឈាម ដោយធ្វើការ វិភាគគុណភាព រាល់ ៣ខែម្តង

# 2. កាត់បន្ថយ និងទប់ស្កាត់ភាពស៊ាំថ្នាំអាតេស៊ីណាត

- ធ្វើការទប់ស្កាត់ការរីករាលដាលភាពស៊ាំថ្នាំអាតេស៊ីណាត ប្តូរថ្នាំព្យាបាលនៅខេត្តប៉ៃលិន ជំនួស ដោយថ្នាំ ម៉ាឡារូន
- បន្តអនុវត្តការហាមប្រើប្រាស់ថ្នាំព្យាបាលជំងឺគ្រុនចាញ់តែមួយមុខ
- បន្តស្វែងរកអ្នកជំងឺដែលមាន មេរោគវិជ្ជមានក្រោយការព្យាបាល ៣ ថ្ងៃ នៅតំបន់ទី៣ ព្រមទាំងធ្វើការឆ្លើយតប តាមរយ:អ្នកស្ម័គ្រចិត្តព្យាបាលជំងឺគ្រុនចាញ់ភូមិ និង បុគ្គលិកសុខាភិបាល
- បន្តការសិក្សាប្រសិទ្ធិភាពថ្នាំ ព្រមទាំងបន្តធ្វើការសិក្សាស្រាវជ្រាវរកមូលហេតុដែលពាក់ព័ន្ធ

# 3. បង្កើនការ ការពារការឆ្លងជំងឺគ្រុនចាញ់

- ធ្វើការគ្របដណ្តប់មុងជ្រលក់ថ្នាំមានប្រសិទ្ធិភាពយូរដែលនៅសេសសល់ ដល់ប្រជាជនគោលដៅ និងប្រជាជនចំណាកស្រុក
- ធ្វើការជ្រលក់មុងចាស់បន្ថែមជាមួយថ្នាំជ្រលក់ដែលមានប្រសិទ្ធិភាពយូរ (អាយខុនម៉ាក់)
- បាញ់ថ្នាំលើជញ្ជាំងផ្ទះនៅកន្លែងដែលមានប្រភពចំលង ចំពោះចំនុចដែលចាំបាច់
- បន្តការសិក្សាប្រសិទ្ធិភាព ភាពទទួលយក នៃថ្នាំលាបបណ្តេញមូស
- ធ្វើការកំណត់ភូមិ តំបន់ដែលមានគ្រុនចាញ់ ដើម្បីឈានដល់ការលប់បំបាត់ជំងឺគ្រុនចាញ់

# 4. បង្កើនការយល់ដឹងផ្លាស់ប្តូរឥរិយាបទចំពោះជំងឺគ្រុនចាញ់

- ផ្តោតលើ ការរកសេវាធ្វើរោគវិនិច្ឆ័យ និងព្យាបាលដែលជិតចំផុត
- ផ្តោតលើជនចំណាកស្រុក ពេលចូលទៅតំបន់គ្រុនចាញ់ និង ពេលត្រឡប់មកវិញ (មានគ្រុនក្តៅ)
- ជាពិសេសភ្ជាប់ជាមួយការប្រើប្រាស់មុងជ្រលក់ថ្នាំនៅពេលធ្វើដំណើរទៅឆ្ងាយពីផ្ទះៗសារជូនដំណឹងនឹងគំរូវសំរាប់ប្រជាជនចល័តនិងចំណាកស្រុក
- បញ្ជាក់និងសង្កត់ធ្ងន់ទៅលើការហាមប្រើថ្នាំតែមួយមុខ ដែលរាជរដ្ឋាភិបាហាមឃាត់ ព្រមទាំងថ្នាំគ្មានគុណភាពរួមទាំងថ្នាំក្លែងក្លាយផងដែរ

# 5. គ្រប់គ្រងកម្មវិធីប្រកបដោយប្រសិទ្ធិភាពរួមបញ្ចូលទាំងប្រព័ន្ធព័ត៌មានសុខាភិបាល និងការតាមដាន

- ធ្វើឲ្យកាន់តែប្រសើរឡើង នូវប្រព័ន្ធពត៌មានគ្រុនចាញ់ MIS រួមទាំងផ្នែកសាធារណៈ សហគមន៍ និង សេវាឯកជន
- ផ្សព្វផ្សាយ វិភាគ ប្រើប្រាស់ទិន្នន័យជាប្រចាំ សំរាប់ឆ្លើយតបបានទាន់ពេល
- ត្រៀមបំរុងទាំងសំភារៈ ថវិការ និងធនធានមនុស្សសំរាប់ធ្វើការទប់ស្កាត់បានទាន់ពេលចំពោះការផ្ទុះជំងឺរាតត្បាត
- ប្រើប្រាស់ប្រព័ន្ធឆ្លើយតបរហ័ស(SMS) សំរាប់ការឆ្លើយតបជំងឺនៅថ្ងៃទី 0 ទី ៣ និង ថ្ងៃទី២៨

# សូមអរគុណ !